**ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន**

**មេធាវី គង់ សំអុន និងមេធាវី Anta GUISSÉ**

រាជធានីភ្នំពេញ/ទីក្រុងប៉ារីស

ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2022, 15:51
CMS/CFO: Sann Rada

**គោរពជូន៖** ចៅក្រម **គង់ ស្រីម** ប្រធានអង្គជំនុំជម្រះតុលាការកំពូល

**ចម្លងជូន៖** ចៅក្រម និងក្រឡាបញ្ជី នៃអង្គជំនុំជម្រះតុលាការកំពូល ភាគីក្នុងសំណុំរឿង ០០២

**កម្មវត្ថុ៖** សេចក្តីសង្កេតរបស់សហមេធាវីការពារក្តីលើអនុស្សរណៈរបស់លោកប្រធានអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២២

---

លោកប្រធានជាទីគោរព!

១. នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ លោកប្រធានបានជូនដំណឹងអំពី "អនុស្សរណៈអន្តរការិយាល័យ" ដែលមានកម្មវត្ថុ "ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២" ("អនុស្សរណៈ")។[1] ក្នុងអនុស្សរណៈនេះ លោកប្រធានក៏បានអញ្ជើញភាគីនានា ក៏ដូចជាផ្នែកផ្សេងៗនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ដើម្បីដាក់សេចក្តីសង្កេតរបស់ពួកគេលើការធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុត ក្នុងសំណុំរឿង ០០២។

២. តាមរយៈសំណោរនេះ សហមេធាវីការពារក្តី ខៀវ សំផន សូមបង្ហាញសេចក្តីសង្កេតរបស់ខ្លួនដូចតទៅ។

## I. សេចក្តីសង្កេតលើគោលការណ៍សាធារណភាពនៃកិច្ចពិភាក្សាដេញដោល និងបណ្តសារ

៣. សាធារណភាពនៃកិច្ចពិភាក្សាដេញដោល គឺជាការធានាមួយដល់គោលការណ៍ការកាត់ក្តីប្រកបដោយយុត្តិធម៌។ សាធារណភាពនៃបណ្តសារពាក់ព័ន្ធនឹងដំណើរការកាត់ក្តី គឺជាការផ្តល់លទ្ធភាពមួយសម្រាប់អ្នកដែលនឹងពិនិត្យមើលព័ត៌មានលម្អិតនៃនីតិវិធីក្នុងសំណុំរឿង ០០២ នាពេលអនាគត ដើម្បីអាចយល់ និងមានការ

---

[1] អនុស្សរណៈអន្តរការិយាល័យរបស់តុលាការកំពូលអំពីការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២ ថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ ឯកសារតុលាការ F71/1/1។

យកចិត្តទុកដាក់លើទឡ្ហីករណ៍នានារបស់ភាគី និងរាល់សេចក្តីសម្រេចរបស់ចៅក្រមដែលបានធ្វើឡើង តាំងពីដំណាក់កាលនៃការស៊ើបអង្កេតរហូតដល់ដំណាក់កាលនៃបណ្តឹងសារទុក្ខ។

៤. ប្រសិនបើនៅដំណាក់កាលស៊ើបអង្កេត ការសម្ងាត់ និងការរក្សាការសម្ងាត់គឺជាវិធានគោល នោះនៅដំណាក់កាលជំនុំជម្រះ ភាគច្រើននៃឯកសារក្នុងសំណុំរឿង ០០២ ត្រូវបានដាក់ជាសាធារណៈ មិនថាដោយសារតែឯកសារទាំងនោះត្រូវបានលើកយកពិភាក្សាដេញដោលជាសាធារណៈនៅក្នុងសវនាការ ឬដោយសារតែត្រូវបានប្រើប្រាស់យ៉ាងក្រាស់ក្រែល និងយ៉ាងលម្អិត ក្នុងសារណារបស់ភាគីនានាក្នុងរឿងក្តី ក៏ដូចជានៅក្នុងសេចក្តីសម្រេចដ៏ច្រើនសម្បើម មិនថាតែនៅដំណាក់កាលជំនុំជម្រះសាលាដំបូង ឬបណ្តឹងសារទុក្ខនៅតុលាការកំពូលនោះឡើយ។ សំណេរ និងសេចក្តីសម្រេចទាំងអស់នេះបានដកស្រង់យ៉ាងទូលំទូលាយនូវឯកសារជាច្រើននៅសំណុំរឿងតាំងពីដំណាក់កាលស៊ើបអង្កេត ប៉ុន្តែក៏មានឯកសារ ធាតុផ្សំផ្សេងទៀតផងដែរ - រួមទាំងសេចក្តីថ្លែងការណ៍របស់សាក្សី និងប្រតិចារឹកសវនាការ - ដែលបានមកពីសំណុំរឿង ០០៣ និង ០០៤។

៥. ដូច្នេះ សហមេធាវីការពារក្តីលោក ខៀវ សំផន សូមទាញចំណាប់អារម្មណ៍របស់តុលាការកំពូល ចំពោះសេចក្តីសម្រេចជាច្រើនដែលបានធ្វើឡើងរវាង សំណុំរឿង ០០២/០១ និង ០០២/០២ ក៏ដូចជាក្រោយការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ ដែលសាលាដំបូងបានដាក់ឯកសារ ធាតុផ្សំដ៏ច្រើនសន្ធឹកសន្ធាប់ ជាសាធារណៈ[2] បានធ្វើឱ្យមេធាវីការពារក្តីអាចដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (អត្ថបទកែប្រែ) ដោយគ្មានការកោសលុបនោះឡើយ។[3]

[2] ជាឧទាហរណ៍ សូមមើល អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង"សេចក្តីសម្រេចបន្ថែមទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំអោយលុបចោលការកោសលុប និងការប្រើប្រាស់រហស្សនាមសម្រាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ និងលើសំណើរបស់នួន ជាសុំអោយធ្វើចំណាត់ថ្នាក់សារជាថ្មីចំពោះសារណាបិទបញ្ចប់កិច្ចពិភាកសាដេញដោលរបស់ពួកគេ" ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ឯកសារតុលាការ **E319/35**; "ការសាកសួរពាក់ព័ន្ធនឹងវិធានការការពារសម្រាប់សាក្សីប្រភេទ ក ឈ្មោះហែម មឿន (2-TCW-976) (សម្ងាត់)" ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ ឯកសារតុលាការ **E319/36**។ អនុស្សរណៈអន្តរការិយាល័យ អង្គជំនុំជម្រះសាលាដំបូង "ឯកសារសម្ងាត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ ដែលស្នើសុំអោយមានការធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ" ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ឯកសារតុលាការ **E467**; "មតិយោបល់លើសំណើសុំធ្វើចំណាត់ប្រភេទឯកសារសម្ងាត់ឡើងវិញ" ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ ឯកសារតុលាការ **E467/1**; ដីកាបង្គាប់អោយធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានានៅក្នុងសំណុំរឿងមកជាឯកសារសាធារណៈ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ឯកសារតុលាការ **E467/6**។

[3] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ កែប្រែនៅថ្ងៃ

៦. ដើម្បីយល់ច្បាស់អំពីដំណើរការកាត់ក្តី និងនីតិវិធី សហមេធាវីការពារក្តីលោក ខៀវ សំផន ពិចារណាជាគោលការណ៍ថា ភស្តុតាងទាំងអស់ដែលត្រូវបានប្រើប្រាស់ ដើម្បីវិនិច្ឆ័យក្តីគាត់ត្រូវតែអាចអនុញ្ញាតអោយអ្នកច្បាប់ អ្នកស្រាវជ្រាវ និងជាទូទៅ សម្រាប់អ្នកណាដែលចាប់អារម្មណ៍ មានសិទ្ធិចូលពិនិត្យមើលបាន។[4]

## II. សេចក្តីសង្កេតលើគោលការណ៍ណែនាំសម្រាប់អនុវត្តក្នុងការចាត់ថ្នាក់ឯកសារឡើងវិញ

៧. លើសពីគោលការណ៍ទូទៅនៃលក្ខណៈសាធារណៈនៃដំណើរការនីតិវិធីដែលគាត់ជាប់ពាក់ព័ន្ធយ៉ាងខ្លាំងនោះ លោក ខៀវ សំផន ច្បាស់ណាស់ថា មានភាពរសើបក្នុងការគោរពឯកជនភាពរបស់បុគ្គលដែលមិនបានជ្រើសរើសធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង និងការគោរពចំពោះហេតុផលដែលនាំមុខសម្រាប់ការចាត់ថ្នាក់ឯកសារសម្ងាត់ ឬសម្ងាត់បំផុតក្នុងអំឡុងពេលជម្រះក្តី។

៨. នៅក្រោមលក្ខខណ្ឌទាំងនេះ គោលការណ៍ដែលបានអនុម័តដោយតុលាការកំពូល ជាពិសេសក្នុងការអនុវត្តតាម សេចក្តីណែនាំអនុវត្ត ECCC/004/2009/Rev.2 និងលម្អិតនៅក្នុងកថាខណ្ឌ ៤ នៃអនុស្សរណៈហាក់ដូចជាសមហេតុផលចំពោះសហមេធាវីការពារក្តី។ លោក ខៀវ សំផន សូមកោតសរសើរជាពិសេសចំពោះការពិចារណាក្នុងកថាខណ្ឌ ៤(ខ) នៃអនុស្សរណៈរបស់លោកប្រធាន ដែលរក្សាទុកនូវគោលការណ៍រក្សាការចាត់ថ្នាក់សម្ងាត់បំផុតលើឯកសារពាក់ព័ន្ធនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក។

៩. ពិតហើយ ដោយយោងតាមអាយុ និងស្ថានភាពសុខភាពរបស់គាត់ សំណុំរឿង ០០២ មានផ្ទុកឯកសារពេទ្យជាច្រើនរបស់លោក ខៀវ សំផន ក៏ដូចជារបស់អតីតជនជាប់ចោទផ្សេងទៀតដែលបានទទួលមរណភាពទៅហើយ។ មិនថាវិញ្ញាបនបត្រវេជ្ជសាស្ត្រសាមញ្ញ មតិអ្នកជំនាញ របាយការណ៍សម្រាកព្យាបាលនៅមន្ទីរពេទ្យ និងឯកសារផ្សេងទៀតដែលធ្វើឡើងដោយអង្គភាពវេជ្ជសាស្ត្រផ្សេងៗនោះទេ ឯកសារទាំងនេះសុទ្ធតែមានទំនាក់ទំនងខាងក្នុងទៅនឹងឯកជនភាពនៃជីវិតឯកជនផ្ទាល់ និងវេជ្ជសាស្ត្ររបស់លោក ខៀវ សំផន ដូច្នេះហើយត្រូវតែនៅរក្សាទុកជាការសម្ងាត់បំផុត។

---

ទី២ ខែតុលា ឆ្នាំ២០១៧ ឯកសារតុលាការ E457/6/4/1។

[4] គោលជំហររបស់មេធាវីការពារក្តីនេះមិនមែនជារឿងថ្មីទេ ហើយក៏ធ្លាប់បានលើកឡើងរួចមក ឧទាហរណ៍ E467, E467/1 និង E467/6 ខាងលើនេះ។

១០. **<u>សរុបសេចក្ដីមក</u>** មេធាវីការពារក្ដី ខៀវ សំផន សូមស្នើតុលាការកំពូល មេត្តាយកសេចក្ដីសង្កេតទាំងនេះ មកពិចារណា ក្នុងវិធីដែលខ្លួននឹងបន្តដំណើរការពិនិត្យលើការចាត់ថ្នាក់ឡើងវិញនៃឯកសារទាំងអស់នៅក្នុង សំណុំរឿង ០០២។

សូមលោកប្រធានមេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

**មេធាវី គង់ សំអុន** **មេធាវី** Anta GUISSÉ